# ផែនការសកម្មភាពប្រចាំឆ្នាំ

## កម្មវិធីអប់រំ

## PROGRAM

## ២០២៤



អង្គការមូលនិធិទ្រទ្រង់កុមារកម្ពុជា

អាសយដ្ឋាន: ផ្ទះលេខ ២២៥ ផ្លូវលេខ ២០០១ ភូមិប៉ប្រកខាងត្បូង សង្កាត់កាកាបទី១ ខណ្ឌពោធិ៍សែនជ័យ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រ កម្ពុជា
ប្រអប់សំបុត្រលេខ: ៨៥០ លេខកូដប្រៃសណីយ៍: ១២៤០៦ ទូរស័ព្ទ/ទូរសារ: ០២៣ ៨៩០ ១៨៦
សារអេឡិចត្រូនិច៖ info@ccafocambodia.org គេហទំព័រ៖ www.ccafocambodia.org

**ចក្ខុវិស័យ៖** យើងចង់ឃើញប្រទេសកម្ពុជាមានសុភមង្គល, មានភាពប្រសើរ នៅក្នុងពិភពលោកមួយដ៏រុងរឿង។

**បេសកកម្ម៖** ជួយកុមារ និង គ្រួសារដែលងាយរងគ្រោះតាមរយៈការអនុវត្តកម្មវិធីមត្តេយ្យសិក្សាសហគមន៍, កម្មវិធីសិក្សាភាសាបរទេស, កម្មវិធីបណ្តុះបណ្តាលជំនាញបំណិនជីវិត, កម្មវិធីថែទាំសុខភាពបឋម, កម្មវិធីអាហារបំប៉នសុខភាព, កម្មវិធីអាហារូបករណ៍ និង កម្មវិធីសិទ្ធិរបស់កុមារ ។ ក្នុងនោះអង្គការធ្វើការផ្តល់មូលនិធិដោយផ្ទាល់ដល់កុមារ និង គ្រួសាររបស់ពួកគេ ឬដោយប្រយោលតាមរយៈអង្គការក្នុងស្រុកនានាដែលអនុវត្តកម្មវិធីមនុស្សធម៌ដើម្បីធ្វើអោយប្រសើឡើងនូវជីវភាពរបស់កុមារ និង គ្រួសារដែលងាយរងគ្រោះ។



**គុណតម្លៃ៖** អង្គការបង្កើតគុណតម្លៃ គឺសម្រាប់បរិយាកាសរបស់ខ្លួន ហើយនិងដល់សិស្ស ព្រមទាំងក្រុមគ្រួសាររបស់ពួកគេ ដែលគុណតម្លៃរួមមានៈ ការទទួលខុសត្រូវ, តម្លាភាព, ការគោរព, មេត្តាករុណា, ការអនុត្តការងារជាក្រុម, ការផ្តល់សិទ្ធិអំណាច, ការយល់ចិត្តគ្នា និង ឱកាសសម្រាប់បង្កើនសេដ្ឋកិច្ចដើម្បីជីវភាពរុងរឿង ។

**១. បុព្វកថា៖** អង្គការមូលនិធិទ្រទ្រង់កុមារកម្ពុជា យល់ឃើញថា ការរីកចម្រើននៃសេដ្ឋកិច្ចក្នុងប្រទេសកើតចេញពីប្រជាពលរដ្ឋដែលមានចំណេះដឹង។ ក្នុងចំណោមការរួមចំណែករបស់អង្គការមិនមែនរដ្ឋាភិបាលទាំងអស់ ភ្នាក់ងាររដ្ឋាភិបាល ម្ចាស់ជំនួយ ក្រុមហ៊ុន អង្គការមូលនិធិទ្រទ្រង់កុមារកម្ពុជា បានដើរតួនាទីក្នុងផ្នែកកម្មវិធីអប់រំ ដែលក្នុងនោះមានកម្មវិធីអប់រំកុមារតូច តាមរយៈការបង្កើត និង អនុវត្តសកម្មភាពគម្រោងមត្តេយ្យសិក្សាសហគមន៍ និងភាសាអង់គ្លេសដល់សិស្សនៅតាមជនបទ ដែលសកម្មភាពបានអនុវត្តអស់រយៈពេល ១៧ ឆ្នាំកន្លងមក និង កំពុងបន្ត។ ជាមួយគ្នានេះដែរអង្គការមូលនិធិទ្រទ្រង់កុមារកម្ពុជាបានជួយសំរបសំរួលទទួល និង ចាត់ចែងនូវមូលនិធិពីមូលនិធិសប្បុរសធម៌អាយហ៊ើបជូន ដល់អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក (ដែលហៅកាត់ថា អនុជំនួយ) ដែលអង្គការទាំងនោះបាន និង កំពុងដំណើរការកម្មវិធីទាក់ទងនឹងការអប់រំនៅព្រះរាជាណាចក្រកម្ពុជាផងដែរ ។

**២. ការបង្កើតផែនការយុទ្ធសាស្ត្រ/ផែនការប្រចាំឆ្នាំ៖** ផែនការយុទ្ធសាស្ត្រគ្របដណ្តប់លើចក្ខុវិស័យ និងបេសកកម្មរបស់អង្គការ ក៏ដូចជាតម្លៃ និងគោលដៅរបស់អង្គការ។ ផែនការយុទ្ធសាស្ត្រ/ផែនការប្រចាំឆ្នាំបានផ្តល់នូវក្របខ័ណ្ឌសម្រាប់ការអភិវឌ្ឍគម្រោង និង គំនិតផ្តួចផ្តើមដែលនឹងជំរុញឱ្យអង្គការអាចធ្វើដំណើរឆ្ពោះទៅមុខប្រកបដោយនិរន្តរភាព ប្រសិទ្ធិភាព និង មានតម្លាភាព របស់អង្គការ ទាំងនេះជាមូលហេតុដែលអង្គការមូលនិធិទ្រទ្រង់កុមារកម្ពុជាបានបង្កើត និង អនុវត្តផែនការយុទ្ធសាស្ត្រ/ផែនការប្រចាំឆ្នាំ ជាប្រចាំ។

**៣.កម្មវិធីអន្តរកម្ម៖** កម្មវិធីអប់រំសម្រាប់កុមារ និង យុវជន នៅជនបទក្នុងព្រះរាជាណាចក្រកម្ពុជា

**ក. គម្រោង៖** ដើម្បីសម្រេចនូវកម្មវិធីដែលបានថ្លែងខាងលើ អង្គការមូលនិធិទ្រទ្រង់កុមារកម្ពុជាបាននិង កំពុងប្រតិបត្តិគម្រោងចំនួនពីរដូចខាងក្រោម៖

**គម្រោង ក៖** ជាគម្រោងដែលអនុវត្តដោយផ្ទាល់៖

**ក.១** គម្រោងគាំទ្រទូទៅ។

**ក.២** គម្រោងមត្តេយ្យសិក្សាសហគមន៍ដើម្បីជីវភាពកាន់តែប្រសើររបស់កុមារក្នុងខេត្តកំពត កំពង់ស្ពឺ តាកែវ និងកំពង់ឆ្នាំង។ ជាគម្រោងដែលអនុវត្តអង្គការបានអនុវត្ត និង រួមសហការជាមួយក្រុមប្រឹក្សាឃុំក្នុងតំបន់គោលដៅ។

**ក.៣** គម្រោងអប់រំភាសាអង់គ្លេសសម្រាប់កុមារក្នុងតំបន់គោលដៅ ក្នុងខេត្តកំពង់ស្ពឺ ដែលមិនគិតកម្រៃ។

**ក.៤** គម្រោងបណ្ណាល័យសហគមន៍ភូមិធ្លោះ។

**គម្រោង ខ៖** ជាគម្រោងដែលប្រតិបត្តិដោយអង្គការក្នុងស្រុកដែលទទួលជំនួយពីមូលនិធិសប្បុរសធម៌អាយហ៊ើប សម្រាប់ការអប់រំកុមារដោយមិនគិតកម្រៃ។

## ៤. ផែនទីតំបន់គោលដៅសម្រាប់អនុវត្តកម្មវិធី

**អង្គការអនុជំនួយ ខេត្តសៀមរាប៖**

១. អង្គការស្វែងយល់លទ្ធភាពអ្នក

២. អង្គការបញ្ញាមូលនិធិអប់រំនៅកម្ពុជា

៣. អង្គការផេតភី លើកកម្ពស់ យុវជន

៤. អង្គការកសាងក្តីសង្ឃឹមកម្ពុជា

**អង្គការអនុជំនួយ៖**

អង្គការឆ្ពោះទៅមុខ ដែលមានទីតាំងនៅខេត្តកំពង់ធំ និង អនុវត្តគម្រោងនៅខេត្តកំពង់ឆ្នាំង

គម្រោងអប់រំភាសាអង់គ្លេសសម្រាប់កុមារក្នុងតំបន់គោលដៅ ក្នុងខេត្តកំពង់ស្ពឺ

គម្រោងមត្តេយ្យសិក្សាសហគមន៍ដើម្បីជីវភាពកាន់តែប្រសើររបស់កុមារក្នុងខេត្ត កំពត កំពង់ស្ពឺ តាកែវ និងកំពង់ឆ្នាំង។



## ក១. គម្រោងគាំទ្រទូទៅ












## ក១.១ ផែនការសកម្មភាព/ផែនការយុទ្ធសាស្រ្ត ឆ្នាំ ២០២៤

| ឋានានុក្រមនៃគោលបំណង | សូចនាករ | មធ្យោបាយនៃការផ្ទៀងផ្ទាត់ | ការសន្មត់ | តម្រូវការ |
|---|---|---|---|---|
| **គោលបំណងរួម៖** កម្មវិធីអប់រំសម្រាប់កុមារ និងយុវជននៅជនបទ ត្រូវបានអនុវត្តដោយអង្គការ។ | តាមរយៈការគាំទ្រពីដៃគូផ្តល់មូលនិធិ និងអង្គការ សិស្សទទួលបានចំណេះដឹង និងអ្នកទទួលផលគម្រោងដទៃទៀត មានជីវភាពប្រសើរឡើង។ | • របាយការណ៍<br>• រូបភាព<br>• ស្ថិតិ | សហគមន៍ និងម្ចាស់ជំនួយនឹងគាំទ្រដល់អង្គការនានា នៅពេលដែលពួកគេមើលឃើញពីវឌ្ឍនភាពរបស់អ្នកទទួលផល។ | ថវិកា, បុគ្គលិក, យានយន្តនិងសម្ភារៈ។ |
| **ទិសដៅទី ១៖** ក្នុងអំឡុងឆ្នាំ ២០២៤ ភាពជាដៃគូជាមួយ មូលនិធិសប្បុរសធម៌អាយហ៊ើប (icF) បានរក្សា។<br>**ទិសដៅទី ២៖** នៅឆ្នាំ២០២៤ អង្គការក្នុងស្រុកចំនួនប្រាំបានទទួលជំនួយពី icF តាមរយៈអង្គការមូលនិធិទ្រទ្រង់កុមារកម្ពុជា។<br>**ទិសដៅទី ៣៖** នៅឆ្នាំ២០២៤ គម្រោងទាំងអស់របស់អង្គការក្នុងស្រុក (អនុជំនួយ) ក្រោមជំនួយឥតសំណងរបស់ icF ត្រូវបានត្រួតពិនិត្យ។<br>**ទិសដៅទី ៤៖** នៅឆ្នាំ២០២៤ ការពិនិត្យឡើងវិញនូវផែនការប្រចាំឆ្នាំ និងការបង្កើតផែនការឆ្នាំ ២០២៥ នឹងត្រូវបានអនុវត្ត។ | **សម្រាប់ទិសដៅទាំងអស់៖**<br>• អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកដែលបានទទួលជំនួយពី icF តាមរយៈ អង្គការមូលនិធិទ្រទ្រង់កុមារកម្ពុជា បានសម្រេចគោលដៅនៃកម្មវិធីរបស់ពួកគេ។<br>• អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកបានអនុវត្តតាមកិច្ចព្រមព្រៀងផ្តល់ជំនួយ ។<br>• ក្រុមការងារគ្រប់គ្រងអង្គការមូលនិធិទ្រទ្រង់កុមារកម្ពុជា អាចគ្រប់គ្រងកម្មវិធីបាន។ | **សម្រាប់ទិសដៅទាំងអស់៖**<br>• របាយការណ៍<br>• រូបភាព | **សម្រាប់ទិសដៅទាំងអស់៖**<br>អ្នកគាំទ្រ/អ្នកសហការនឹងផ្តល់ការគាំទ្រ។ | ថវិកា, បុគ្គលិក, យានយន្តនិងសម្ភារៈ។ |

| | | | | |
|---|---|---|---|---|
| | • របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សកម្មភាពបានអនុវត្តតាមតម្រូវការរបស់រាជរដ្ឋាភិបាល និងម្ចាស់ជំនួយ។ | | | |
| **លទ្ធផលរំពឹងទុក៖**<br>**១.** ភាពជាដៃគូជាមួយ icF, អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកដែលទទួលជំនួយពី icF និងអង្គការដៃគូផ្សេងទៀតត្រូវបានរក្សា។<br><br>**២.** សមត្ថភាពនៃក្រុមគ្រប់គ្រងត្រូវបានពង្រឹង។<br><br>**៣.** ទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាល និង ដៃគូសហការនានាដែលអនុវត្តក្នុងវិស័យអប់រំ បានពង្រឹង។ | **សម្រាប់លទ្ធផលរំពឹងទុកទាំងអស់៖**<br>• កម្មវិធីរបស់អង្គការមូលនិធិទ្រទ្រង់កុមារកម្ពុជា អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកដែលទទួលជំនួយពី icF & មូលនិធិអនុជំនួយបានដំណើរការ។<br>• ការចូលរួមក្នុងបណ្ដាញ អង្គការដែលអនុវត្តក្នុងវិស័យអប់រំ និង ដៃគូសហការដទៃទៀតត្រូវបានពង្រីក។ | **សម្រាប់លទ្ធផលរំពឹងទុកទាំងអស់៖**<br>• របាយការណ៍។ | **សម្រាប់លទ្ធផលរំពឹងទុកទាំងអស់៖**<br>អ្នកគាំទ្រ/អ្នកសហការនឹងផ្តល់ការគាំទ្រ។ | ថវិកា, បុគ្គលិក, យានយន្តនិងសម្ភារៈ។ |

### ក.១.២ កាលបរិច្ឆេទនៃការអនុវត្តន៍សកម្មភាព

| លេខរៀងសកម្មភាព | ការរៀបរាប់នៃសកម្មភាព | ខែនៃឆ្នាំ ២០២៤ | | | | | | | | | | | | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | |
| ១. | អនុវត្តការត្រួតពិនិត្យប្រចាំខែនៃកម្មវិធីដែលដំណើរការរបស់អង្គការមូលនិធិទ្រទ្រង់កុមារកម្ពុជា និង អង្គការក្នុងស្រុកដែលទទួលជំនួយតាមរយៈអង្គការមូលនិធិទ្រទ្រង់កុមារកម្ពុជា។ | X | X | X | X | X | X | X | X | X | X | X | X | ក្រុមអ្នកគ្រប់គ្រងអង្គការ |
| ២. | ធ្វើការត្រួតពិនិត្យផែនការយុទ្ធសាស្ត្រ និងការអភិវឌ្ឍន៍ផែនការឆ្នាំបន្ទាប់។ | | | | | | X | | | X | | | | ក្រុមអ្នកគ្រប់គ្រងអង្គការ |
| ៣. | ការបង្កើត និងអនុវត្តផែនការរៃអង្គាសប្រាក់។ | X | X | X | X | X | X | X | X | X | X | X | X | ក្រុមអ្នកគ្រប់គ្រងអង្គការ |
| ៤. | ក្រុមហ៊ុនគណនេយ្យអនុវត្តសវនកម្មនៃហិរញ្ញវត្ថុឆ្នាំ ២០២៣សម្រាប់អង្គការ ។ | X | X | X | X | X | X | | | | | | | អ្នកគ្រប់គ្រងផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ |
| ៥. | អនុវត្តសកម្មភាពផ្សេងៗទៀត រួមមាន៖ ប្រជុំជាមួយអាជ្ញាធរមូលដ្ឋាន បណ្ដាញអង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នក្រសួង នានា និង ចូលរួមវគ្គបណ្ដុះបណ្ដាលគ្រប់គ្រង។ | X | X | X | X | X | X | X | X | X | X | X | X | ក្រុមអ្នកគ្រប់គ្រងអង្គការ |

**-ចប់ ក.១ គម្រោងគាំទ្រទូទៅ-**

ក.២ គម្រោងមត្តេយ្យសិក្សាសហគមន៍ដើម្បីជីវភាពកាន់តែប្រសើររបស់កុមារក្នុងខេត្តកំពត កំពង់ស្ពឺ តាកែវ និងកំពង់ឆ្នាំង។ ជាគម្រោងដែលអនុវត្តអង្គការបានអនុវត្ត និង រួមសហការជាមួយក្រុមប្រឹក្សាឃុំក្នុងតំបន់គោលដៅ។.












**ក.២.១ ចំនួនមត្តេយ្យសិក្សាសហគមន៍៖ ចំនួន ២៣ ដែលមានរាយដូចខាងក្រោម៖**

**ក.២.១.១ ខេត្តកំពត ៖** សរុបចំនួន ១៦ សាលា៖ ១២ សាលា ក្នុងស្រុកបន្ទាយមាស, ២ សាលាក្នុងស្រុកកំពង់ត្រាច, ១សាលាក្នុងស្រុក ឈូក, និង ១សាលាក្នុងស្រុកជុំគីរី។

**ក.២.១.២ ខេត្តកំពង់ស្ពឺ ៖** សរុបចំនួន ២ សាលា៖ ២ សាលា ក្នុងស្រុកសាមគ្គីមុនីជ័យ (អតីតស្រុកឧដុង្គ)។

**ក.២.១.៣ ខេត្តកំពង់ឆ្នាំង៖** សរុបចំនួន ៤ សាលា៖ ៤ សាលា ក្នុងស្រុកកំពង់លែង។

**ក.២.១.៤ ខេត្តតាកែវ ៖** សរុបចំនួន ១ សាលា៖ ១ សាលា ក្នុងស្រុកទ្រាំង។

**សាលាមត្តេយ្យស្តង់ដារអេប្បបរមា៖** ក្នុងចំណោមសាលាមត្តេយ្យសិក្សាសហគមន៍ទាំង ២៣ សាលាមត្តេយ្យសិក្សាចំនួន ៥ បានក្លាយជាសាលាមត្តេយ្យស្តង់ដារអេប្បបរមាដែលត្រូវបានទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា។ អង្គការមូលនិធិទ្រទ្រង់កុមារកម្ពុជា មិនទទួលខុសត្រូវលើប្រាក់បៀវត្សរ៍សម្រាប់គ្រូបង្រៀនទាំង៥នាក់នេះទេ ព្រោះគ្រូបង្រៀនទទួលបានជំនួយហិរញ្ញវត្ថុពីក្រុមប្រឹក្សាឃុំ និងក្រសួងអប់រំ យុវជន និងកីឡា។ ទោះជាយ៉ាងណាក៏ដោយ អង្គការមូលនិធិទ្រទ្រង់កុមារកម្ពុជា នៅតែបន្តគាំទ្រសាលារៀនទាំង ៥ នេះ ដែលត្រូវការជំនួយបន្ថែមលើសម្ភារៈបង្រៀន ការបណ្តុះបណ្តាលគ្រូ និងការថែទាំថ្នាក់រៀន។

**ការគាំទ្រដោយប្រយោល៖** ក្នុងចំណោមសាលាមត្តេយ្យសិក្សាសហគមន៍ចំនួន២៣ សាលាមត្តេយ្យសិក្សាសហគមន៍ចំនួន ៤ ត្រូវការជំនួយបន្ថែមលើសម្ភារៈបង្រៀន ការបណ្តុះបណ្តាលគ្រូ និងការថែទាំថ្នាក់រៀន ដែលទាមទារការគាំទ្រពី អង្គការមូលនិធិទ្រទ្រង់កុមារកម្ពុជា។

**ក.២.២ ក្រុមគោលដៅ ៖** កុមារតូចអាយុ ៣ ដល់ក្រោម ៦ឆ្នាំ។

**ក.២.៣ ចំនួនសិស្ស ៖** តាមផែនការ កុមារតូចចំនួន ៩៥៥ នាក់ (កុមារី ២៣៣នាក់)

## ក.២.៤ ផែនទីតំបន់គោលដៅសម្រាប់អនុវត្តគម្រោង

សាលាមត្តេយ្យចំនួន ៤៖ សាលាមត្តេយ្យចំនួន ២ ទទួលបានការគាំទ្ររួមទាំងប្រាក់បៀវត្សរ៍ និងសម្ភារៈបង្រៀន និង សាលាមត្តេយ្យសិក្សា ២ ផ្សេងទៀតទទួលបានសម្ភារៈបង្រៀនពីអង្គការមូលនិធិទ្រទ្រង់កុមារកម្ពុជា។

សាលាមត្តេយ្យចំនួន២៖ សាលាមត្តេយ្យទាំង២ ទទួលបានការគាំទ្ររួមទាំងប្រាក់បៀវត្សរ៍ និងសម្ភារៈបង្រៀនពីអង្គការមូលនិធិទ្រទ្រង់កុមារកម្ពុជា។

សាលាមត្តេយ្យចំនួន ១៦៖ សាលាមត្តេយ្យចំនួន ៩ ទទួលបានការគាំទ្ររួមទាំងប្រាក់បៀវត្សរ៍ និងសម្ភារៈបង្រៀន ចំណែកសាលាមត្តេយ្យចំនួន ៧ ផ្សេងទៀតទទួលបានតែសម្ភារៈបង្រៀនពីអង្គការមូលនិធិទ្រទ្រង់កុមារកម្ពុជា។




សាលាមត្តេយ្យចំនួន ១៖ សាលាមត្តេយ្យសិក្សានេះទទួលបានការគាំទ្ររួមទាំងប្រាក់បៀវត្សរ៍ និងសម្ភារៈបង្រៀនពីអង្គការមូលនិធិទ្រទ្រង់កុមារកម្ពុជា។

## ក.២.៥ ផែនទីតំបន់គោលដៅសម្រាប់អនុវត្តគម្រោងក្នុងខេត្តកំពត



## ក.២.៦ ផែនទីតំបន់គោលដៅសម្រាប់អនុវត្តគម្រោងក្នុងខេត្តកំពង់ស្ពឺ



ក.២.៧ ផែនទីតំបន់គោលដៅសម្រាប់អនុវត្តគម្រោងក្នុងស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង




សាលាមត្តេយ្យ ២ (រៀនពេលព្រឹក) មិនគាំទ្រប្រាក់ខែគ្រូ គាំទ្រតែសំភារៈបង្រៀន និង ដទៃទៀត។

សាលាមត្តេយ្យ ២ (រៀនពេលព្រឹក)

## ក.២.៨ ផែនទីតំបន់គោលដៅសម្រាប់អនុវត្តគម្រោងក្នុងស្រុកទ្រាំង ខេត្តតាកែវ

សាលាមត្តេយ្យ ១ (រៀនពេលព្រឹក)



## ក.២.៩ ផែនការសកម្មភាព/ផែនការយុទ្ធសាស្ត្រ ឆ្នាំ ២០២៤

| ឋានានុក្រមនៃគោលបំណង | សូចនាករ | មធ្យោបាយនៃការផ្ទៀងផ្ទាត់ | ការសន្មត់ | តម្រូវការ |
|---|---|---|---|---|
| **គោលបំណង:** សិទ្ធិរបស់កុមារក្នុងការចូលរួមក្នុងវិស័យអប់រំកើនឡើង។ | • សហគមន៍គោរពសិទ្ធិរបស់កុមារ។<br>• កុមាររស់នៅក្នុងភាពសុខដុម។<br>• កុមារបានទទួលចំណេះដឹង។<br>• កាត់បន្ថយជំងឺ។ | • ករណីសិក្សា។<br>• កំណត់ត្រាស្ថិតិ។ | • សហគមន៍នឹងគាំទ្រអង្គការ ខណៈដែលពួកគេមើលឃើញការរីកចម្រើនរបស់កុមារ។<br><br>• ធ្វើឱ្យប្រសើរឡើងនូវចំណេះដឹង និង សុខភាពរបស់កុមារគឺជាលទ្ធផលដោយផ្ទាល់នៃកម្មវិធីរបស់អង្គការ។ | ថវិកា, បុគ្គលិក, យានយន្តនិងសម្ភារៈ។ |
| **ទិសដៅទី១៖** ក្នុងអំឡុងឆ្នាំសិក្សា ២០២៣ ២០២៤ កុមារ ៩៥៥ នាក់ នៅក្នុងតំបន់គោលដៅនឹងចូលរួមក្នុងកម្មវិធីមត្តេយ្យសហគមនិភូមិ។<br><br>**ទិសដៅទី២៖** ក្នុងឆ្នាំ២០២៤ សមត្ថភាពបង្រៀនរបស់គ្រូទាំង ២៣ នាក់ នឹងត្រូវបានធ្វើឱ្យប្រសើរឡើងតាមរយៈការប្រជុំបច្ចេកទេសប្រចាំខែ។ | • សាលាមត្តេយ្យទាំងអស់បន្តដំណើរការ។<br><br>• សិស្សមានអាយុក្រោម ៦ឆ្នាំ ចំនួន ១២៥ នាក់ បានបញ្ជូនទៅរៀននៅថ្នាក់ទី១ សម្រាប់ឆ្នាំសិក្សា ២០២៤ ២០២៥។<br><br>• គ្រូមានជំនាញបង្រៀន។ | **គ្របដណ្តប់គ្រប់គោលបំណងនិងលទ្ធផល៖**<br><br>• កំណត់ត្រាវត្តមានសិស្ស។<br><br>• **ផ្សេងៗទៀត៖** ករណីសិក្សា, រូបថត, Facebook, គេហទំព័រនិងរបាយការណ៍នានា។ | • ឪពុកម្តាយនិងកូនៗនឹងចូលរួមក្នុងកម្មវិធី។<br><br>• អ្នកគាំទ្រអង្គការ/អ្នកសហការនឹងជួយ។<br><br>• គ្រោះមហន្តរាយធម្មជាតិ (ទឹកជំនន់) នឹងមិនប៉ះពាល់ដល់គម្រោងនេះ។ | ថវិកា, បុគ្គលិក, យានយន្តនិងសម្ភារៈ។ |

| | | | | |
|---|---|---|---|---|
| **ទិសដៅទី៣៖** ក្នុងឆ្នាំ២០២៤ សមត្ថភាពសិស្សដែលមានអាយុក្រោម ៦ ឆ្នាំ ចំនួន ១២៥ នាក់ចូលរួមការវាស់ចំណេះដឹងចំនួន ៣ដង (ខែ )។ | | | | |
| **លទ្ធផលរំពឹងទុក**<br>**១.** ភាពយកចិត្តទុកដាក់របស់ឪពុកម្តាយ, គ្រូ, និងសហាគមន៍សម្រាប់សិទ្ធិកុមារ និង កម្មវិធីអប់រំបានកើនឡើង។<br><br>**២.** សិស្សទទួលបានចំណេះដឹងដោយសារវិធីសាស្រ្តបង្រៀនរបស់គ្រូ។<br><br>**៣.** សិស្សអាយុក្រោម ៦ ឆ្នាំ ដែលត្រូវរៀននៅថ្នាក់ទី១ ក្នុងឆ្នាំសិក្សា ២០២៤ ២០២៥ ចំនួន ១២៥ នាក់ មានចំណេះដឹងតាមរយៈការធ្វើតេស្ត។<br><br>**៤.** សាលាទាំង ២៣ មាននិរន្តរភាពតាមរយៈការបន្តជួយពីក្រុមប្រឹក្សាឃុំ និង ម្ចាស់ជំនួយ។ | **១.** ការផ្លាស់ប្តូរនៅក្នុងចំណេះដឹងនិងការយល់ដឹងស្តីពីសិទ្ធិកុមារនិងសមភាពយេនឌ័រនៅក្នុងចំណោម៖<br>• គ្រូនិងបុគ្គលិកផ្សេងទៀត។<br>• ឪពុកម្តាយ។<br>• សមាជិកសហាគមន៍ ផ្សេងទៀត។<br><br>**២.** គុណភាពនៃការអប់រំមានភាពប្រសើរឡើងដូច្នេះចំនេះដឹងរបស់កុមារកើនឡើង។<br><br>**៣.** ការចូលរួមរបស់កុមារតូចនៅតាមជនបទក្នុងកម្មវិធីសាលាមត្តេយ្យបានកើនឡើង។ | | • ឪពុកម្តាយនិងកូននឹងចូលរួមក្នុងកម្មវិធី។<br><br>• ម្ចាស់ជំនួយនឹងបន្តគាំទ្រដល់អង្គការ ។ | ថវិកា, បុគ្គលិក, យានយន្តនិងសម្ភារៈ។ |

| | | | |
|---|---|---|---|
| **សកម្មភាពចម្បងៗ**<br>**១**-សាលាមត្តេយ្យបន្តផ្តល់ការអប់រំដល់សិស្ស ។<br><br>**២**- រក្សាការទំនាក់ទំនងជាមួយអ្នកគាំទ្រនិងអ្នកសហការ។<br><br>**៣**- រៀបចំការប្រជុំប្រចាំខែនិងប្រចាំឆ្នាំនិងការអនុវត្តការរៃអង្គាសថវិកា។<br><br>**៤**- ក្រុមគ្រប់គ្រងបន្តកម្មវិធីត្រួតពិនិត្យ។<br><br>**៥**-បញ្ជូនរបាយការណ៍ទៅម្ចាស់ជំនួយនិងរដ្ឋាភិបាល។ | អនុវត្តទទួលបានជោគជ័យនៃសកម្មភាពត្រូវបានវាស់ដោយសូចនាករនិងមធ្យោបាយនៃការផ្ទៀងផ្ទាត់ពីផ្នែកគោលបំណងខាងលើ។ | ដូចគ្នាដូចដែលបានរៀបរាប់ពីគោលដៅគោលបំណងនិងផ្នែកលទ្ធផលខាងលើ។ | ដូចគ្នាដូចដែលបានរៀបរាប់ពីគោលដៅគោលបំណងនិងផ្នែកលទ្ធផលខាងលើ។ |

## ក.២.១០ កាលបរិច្ឆេទនៃការអនុវត្តន៍សកម្មភាព

| លេខរៀងសកម្មភាព | ការរៀបរាប់នៃសកម្មភាព | ខែនៃឆ្នាំ ២០២៣ | | ខែនៃឆ្នាំ ២០២៤ | | | | | | | | | | | | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | |
| ១. | សិស្សបន្តការសិក្សានៅមត្តេយ្យសិក្សាសហគមន៍ទាំង ២៣ ថ្នាក់។ | | X | X | X | X | X | X | X | X | X | X | | | | គ្រូ |
| ២. | បញ្ជូនឈ្មោះសិស្ស អាយុ៦ឆ្នាំ ឬ ៧០ ខែ ចូលរៀនថ្នាក់ទី១សាលារដ្ឋ ។ | | | | | | | | | | | | | X | | គ្រូ និង អ្នកសម្របសម្រួលគំរោង |
| ៣. | ស្រង់ស្ថិតិកុមារក្នុងភូមិគោលដៅ និង ចុះឈ្មោះសិស្សសំរាប់ឆ្នាំសិក្សា ២០២៤-២០២៥។ | | | | | | | | | | | | X | X | | គ្រូ និង អ្នកសម្របសម្រួលគំរោង |
| ៤. | គ្រូចូលរួមបណ្តុះបណ្តាល និង ផលិតសម្ភារៈឧបទេស | X | X | X | X | X | X | X | X | X | X | X | X | X | X | គ្រូ |
| ៥. | គ្រូតពិនិត្យសកម្មភាពគម្រោងដើម្បីពីនិត្យពីការអនុវត្តរបស់គ្រូ និង ចំណេះដឹងរបស់សិស្ស | X | X | X | X | X | X | X | X | X | X | X | | | X | ក្រុមអ្នកចាត់ចែងគំរោង |
| ៦. | គ្រូ និងអ្នកគ្រប់គ្រងចូលរួមប្រជុំផែនការយុទ្ធសាស្ត្រ | | | | | | | | X | | | | | X | | គ្រូ និង អ្នកគ្រប់គ្រង |
| ៧. | គ្រូអនុវត្តតេស្តចំណេះដឹងរបស់សិស្សដែលមានអាយុក្រោម ៦ ឆ្នាំ | | X | | | X | | | | X | | | | | | គ្រូ |
| ៨. | គ្រូ និងឬ អ្នកគ្រប់គ្រងចូលរួមសិក្ខាសាលាជាមួយក្រុមប្រឹក្សាឃុំនៅតាមតំបន់គោលដៅ។ | X | X | X | X | X | X | X | X | X | X | X | X | X | X | គ្រូ និង អ្នកគ្រប់គ្រង |
| ៩. | ធ្វើសកម្មភាពដទៃផ្សេងៗទៀតដូចជា៖ ចូលរួមប្រជុំជាមួយបណ្តាញអង្គការ, ក្រសួងពាក់ព័ន្ធនានា, វគ្គបណ្តុះបណ្តាលអ្នកគ្រប់គ្រង ។ល។ | X | X | X | X | X | X | X | X | X | X | X | X | X | X | ក្រុមអ្នកចាត់ចែងគំរោង |

**-ចប់ ក.២ គម្រោងមត្តេយ្យសិក្សាសហគមន៍-**

## ក.៣ គម្រោងអប់រំភាសាអង់គ្លេសសម្រាប់កុមារក្នុងតំបន់គោលដៅ ក្នុងខេត្តកំពង់ស្ពឺ ដែលមិនគិតកម្រៃ។
















**ក.៣.១ តំបន់គោលដៅ** ៖ ឃុំ ពាំងល្វា, ស្រុក សាមគ្គីមុនីជ័យ និង ឃុំ សំរោងទង ស្រុកសំរោងទង, ខេត្ត កំពង់ស្ពឺ ប្រទេស កម្ពុជា ។

**ក.៣.២ អ្នកទទួលផល** ៖ កុមារអាយុពី ៦ ឆ្នាំ ដល់ ១៦ ឆ្នាំ សំរាប់សិស្សសាលាភាសាអង់គ្លេស។

**ក.៣.៣ ចំនួនអ្នកទទួលផល** ៖ ៣៥០ នាក់

**ក.៣.៤ ផែនទីតំបន់គោលដៅគម្រោងខេត្តកំពង់ស្ពឺ**



## ក.៣.៤.១ ផែនទីតំបន់គោលដៅគម្រោងក្នុងឃុំ ពាំងល្វា ស្រុក សាមគ្គីមុនីជ័យ ខេត្តកំពង់ស្ពឺ






**មជ្ឈមណ្ឌលអប់រំ មាតុភូមិខ្មែរ៖** ភូមិត្រពាំងអណ្តូង,ឃុំពាំងល្វា,ស្រុកសាមគ្គីមុនីជ័យ,ខេត្តកំពង់ស្ពឺ

## ក.៣.៤.២ ផែនទីតំបន់គោលដៅគម្រោងក្នុងឃុំ សំរោងទង ស្រុក សំរោងទង ខេត្តកំពង់ស្ពឺ

**ផែនទីឃុំ សំរោងទង**



## ក.៣.៥ ផែនការសកម្មភាព/ផែនការយុទ្ធសាស្ត្រ ឆ្នាំ ២០២៤

| ឋានានុក្រមនៃគោលបំណង | សូចនាករ | មធ្យោបាយនៃការផ្ទៀងផ្ទាត់ | ការសន្មត់ | តម្រូវការ |
|---|---|---|---|---|
| **គោលបំណង:** សិទ្ធិរបស់កុមារក្នុងការចូលរួមក្នុងវិស័យអប់រំ, កម្មវិធីថែទាំសុខភាព,អាហារូបត្ថម្ភនិងសិល្បៈកើនឡើង។ | • សហគមន៍គោរពសិទ្ធិរបស់កុមារ។<br>• កុមាររស់នៅក្នុងភាពសុខដុម។<br>• កុមារបានទទួលចំណេះដឹង។<br>• កាត់បន្ថយជំងឺ។ | • ករណីសិក្សា។<br>• កំណត់ត្រាស្ថិតិ។ | • សហគមន៍នឹងគាំទ្រអង្គការខណៈដែលពួកគេមើលឃើញការរីកចម្រើនរបស់កុមារ។<br>• ធ្វើឱ្យប្រសើរឡើងនូវចំណេះដឹង និង សុខភាពរបស់កុមារគឺជាលទ្ធផលដោយផ្ទាល់នៃកម្មវិធីរបស់អង្គការ។ | ថវិកា, បុគ្គលិក, យានយន្តនិងសម្ភារៈ។ |
| **ទិសដៅ៖** ក្នុងអំឡុងឆ្នាំ ២០២៤ (ឆ្នាំសិក្សា២០២៣-២០២៤) កុមារ ៣៥០នាក់ នឹងចូលរួមក្នុងកម្មវិធីគម្រោងភាសាអង់គ្លេស និងកម្មវិធីសុខភាពបឋម កម្មវិធីអប់រំសុខភាពកុមារី,អាហារូបត្ថម្ភ ,កីឡា និង សិល្បៈ។ | **គ្រប់ដណ្តប់ទីសដៅ៖**<br>• ចំណេះដឹងរបស់កុមារមានភាពប្រសើរតាមរយៈការសិក្សាភាសាអង់គ្លេស,ការអានសៀវភៅ,រៀនតាមរយៈ យូធូប និង ចូលរួមសកម្មភាពនានាលើផ្នែកបំណិនជីវិត។<br>• កុមារមានសុខភាពល្អ និង សុវត្ថិភាពប្រសើរ។ | **គ្របដណ្តប់ទីសដៅនិងលទ្ធផលរំពឹងទុក៖**<br>• កំណត់ត្រាវត្តមានសិស្ស។<br>• **ផ្សេងៗទៀត៖** ករណីសិក្សា, រូបថត, វិញ្ញាបនបត្រនៃការបណ្តុះបណ្តាល, Facebook, គេហទំព័រនិង | **គ្របដណ្តប់ទីសដៅ៖**<br>• ឪពុកម្តាយនិងកូនៗនឹងចូលរួមក្នុងកម្មវិធី។<br>• អ្នកគាំទ្រអង្គការ/អ្នកសហការនឹងជួយ។<br>• គ្រោះមហន្តរាយធម្មជាតិ (ទឹកជំនន់) នឹងមិនប៉ះពាល់ដល់គម្រោងនេះ។ | ថវិកា, បុគ្គលិក, យានយន្តនិងសម្ភារៈ។ |
| **លទ្ធផលរំពឹងទុក**<br>**១.** ភាពយកចិត្តទុកដាក់របស់ឪពុកម្តាយ, គ្រូ, និងសហគមន៍ | **១.**ការផ្លាស់ប្តូរនៅក្នុងចំណេះដឹងនិងការយល់ដឹងស្តីពីសិទ្ធិកុមារនិងសមភាពយេនឌ័រនៅក្នុងចំណោម៖ | | • ឪពុកម្តាយនិងកូននឹងចូលរួមក្នុងកម្មវិធី។ | ថវិកា, បុគ្គលិក, យានយន្តនិងសម្ភារៈ។ |

| | | | | |
|---|---|---|---|---|
| សម្រាប់សិទ្ធិកុមារ និង កម្មវិធីអប់រំបានកើនឡើង។<br><br>២. សិស្សទទួលបានចំណេះដឹងតាមរយៈកម្មវិធីសិក្សាភាសាអង់គ្លេស តាមឯកសារបង្កើតដោយក្រុមគ្រូ English for Beginner, សៀវភៅ English for Children។<br>៣. វិធីសាស្ត្របង្រៀនរបស់គ្រូបានប្រសើរឡើង។<br><br>៤. សមត្ថភាពរបស់ក្រុមអ្នកចាត់ចែងបានពង្រឹង។<br><br>៥. បណ្តាញ អង្គការក្រៅរដ្ឋាភិបាល/ដៃគូរសហការពង្រឹងនិងកើនឡើង។ | •គ្រូនិងបុគ្គលិកផ្សេងទៀត។<br>•ឪពុកម្តាយ។<br>•សមាជិកសហគមន៍ផ្សេងទៀត។<br><br>២.គុណភាពនៃការអប់រំមានភាពប្រសើរឡើងដូច្នេះចំណេះដឹងរបស់កុមារកើនឡើង។<br><br>៣. ការចូលរួមរបស់កុមារក្នុងកម្មវិធីអប់រំភាសាអង់គ្លេស, ថៃទាំសុខភាព, និងសកម្មភាពសិល្បៈផ្សេងទៀតបានកើនឡើង។<br><br>៤. សុខភាពរបស់កុមារមានភាពប្រសើរឡើង។<br><br>៥. កម្មវិធីរបស់អង្គការដំណើរការ ។<br>៦. ការចូលរួមក្នុងបណ្តាញអង្គការក្រៅរដ្ឋាភិបាល / អ្នកសហការកាន់តែពង្រីក។ | របាយការណ៍នានា។ | • អ្នកគាំទ្រអង្គការ/ដៃគូរសហប្រតិបត្តិការនឹងផ្តល់នូវការសហការគ្នាល្អ។<br><br>• ម្ចាស់ជំនួយនឹងបន្តគាំទ្រដល់អង្គការ ។ | |
| **សកម្មភាពចម្បងៗ**<br>១. បន្តផ្តល់ការអប់រំដល់សិស្ស។<br>២. រក្សាទំនាក់ទំនងជាមួយអ្នកគាំទ្រនិងដៃគូរសហការ ។<br>៣. ក្រុមអ្នកគ្រប់គ្រងបន្តការត្រួតពិនិត្យគម្រោង។ | អនុវត្តទទួលបានជោគជ័យនៃសកម្មភាពត្រូវបានវាស់ដោយសូចនាករនិងមធ្យោបាយនៃការផ្ទៀងផ្ទាត់ពីផ្នែកគោលបំណងខាងលើ។ | | ដូចគ្នាដូចដែលបានរៀបរាប់ពីគោលបំណង ទិសដៅ និងផ្នែកលទ្ធផលរំពឹងទុក។ | ដូចគ្នាដូចដែលបានរៀបរាប់ពីគោលបំណង ទិសដៅ និងផ្នែកលទ្ធផលរំពឹងទុក។ |

| | | | |
|---|---|---|---|
| ៤. ផ្តល់របាយការណ៍ទៅម្ចាស់ជំនួយ និង រាជរដ្ឋាភិបាល ។ | | | |

### ក.៣.៦ កាលបរិច្ឆេទនៃការអនុវត្តសកម្មភាព ២០២៣ - ២០២៤

| លេខរៀងសកម្មភាព | ការរៀបរាប់នៃសកម្មភាព | ខែនៃឆ្នាំ ២០២៣ | | ខែនៃឆ្នាំ ២០២៤ | | | | | | | | | | | | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | |
| ១. | សិស្សបន្តការសិក្សានៅសាលា ភាសាអង់គ្លេស។ | | X | X | X | X | X | X | X | X | X | X | | | X | គ្រូ និង ប្រធានផ្នែក |
| ២. | បណ្តុះបណ្តាលជំនាញដល់គ្រូបង្រៀន។ | | X | X | X | X | X | X | X | X | x | X | X | X | X | ប្រធានផ្នែក |
| ៣. | ចុះឈ្មោះសិស្សសំរាប់ឆ្នាំសិក្សា ២០២៤-២០២៥ | X | | | | | | | | | | | | X | X | គ្រូ និង ប្រធានផ្នែក |
| ៤. | អនុវត្តសកម្មភាពរៃអង្គាសថវិកា។ | X | X | X | X | X | X | X | X | X | X | X | X | X | X | នាយកប្រតិបត្តិ, ប្រធានផ្នែកអប់រំ |
| ៥. | ការធ្វើការត្រួតពិនិត្យនិងការវាយតម្លៃនៃកម្មវិធី។ | X | X | X | X | X | X | X | X | X | X | X | X | X | X | ក្រុមអ្នកចាត់ចែងគំរោង |
| ៦. | ប្រជុំប្រចាំខែនិងសិក្ខាសាលាស្តីពីផែនការយុទ្ធសាស្រ្ត។ | X | X | X | X | X | X | X | X | X | X | X | X | X | X | ក្រុមអ្នកចាត់ចែងគំរោង |
| ៧. | ផ្តល់របាយការណ៍ទៅឱ្យម្ចាស់ជំនួយ និង រាជរដ្ឋាភិបាលជាទៀងទាត់។ | X | X | X | X | X | X | X | X | X | X | X | X | X | X | ក្រុមអ្នកចាត់ចែងគំរោង |
| ៨. | ធ្វើសកម្មភាពដទៃផ្សេងៗទៀតដូចជា៖ ចូលរួមប្រជុំជាមួយបណ្តាញអង្គការ, ក្រសួងពាក់ព័ន្ធនានា, វគ្គបណ្តុះបណ្តាលអ្នកគ្រប់គ្រង ។ល។ | X | X | X | X | X | X | X | X | X | X | X | X | X | X | ក្រុមអ្នកចាត់ចែងគម្រោង |
| ៩. | អនុវត្តសកម្មភាពសុខភាពបឋមដល់សិស្ស | | X | X | X | X | X | X | X | X | X | X | | | X | គ្រូ និង បុគ្គលិក |
| ១០. | ការផ្តល់អាហារសម្រន់ដល់សិស្ស១ដងក្នុងមួយសប្តាហ៍ | | | X | X | X | X | X | X | X | X | X | X | X | | គ្រូ និង ប្រធាន |
| ១១. | កម្មវិធីអប់រំសុខភាពកុមារី១ដងក្នុងមួយសប្តាហ៍ | | X | X | X | X | X | X | X | X | X | X | | | X | គ្រូ និង ប្រធាន |

**-ចប់ ក.៣ គម្រោងអប់រំភាសាអង់គ្លេសសម្រាប់កុមារ-**

### ក.៤ គម្រោងបណ្ណាល័យសហគមន៍ភូមិឆ្នោះ



**បុព្វបទ៖** បណ្ណាល័យគឺជាផ្នែកមួយដែលស្ថិតនៅជាមួយសាលាមត្តេយ្យសិក្សាសហគមន៍ភូមិឆ្នោះ ក្នុងឃុំ អង្គកែវ ស្រុកទ្រាំង ខេត្តតាកែវ ជាគម្រោងសម្រាប់ផ្តល់ជូនសិស្សានុសិស្ស និងសហគមន៍នូវសៀវភៅរឿងជាច្រើនសម្រាប់អាន សម្រាប់ជាចំណេះដឹងរបស់ពួកគេ។ បណ្ណាល័យមានកន្លែងសម្រាប់សិស្សានុសិស្ស និងសហគមន៍អានសៀវភៅ ប៉ុន្តែពួកគេអាចខ្ចីសៀវភៅអាននៅផ្ទះបាន។ បណ្ណាល័យក៏បើកសម្រាប់សិស្សមត្តេយ្យសិក្សាដែលចូលចិត្តស្តាប់ការនិទានរឿងដោយបណ្ណារក្ស។ នៅឆ្នាំ២០២២ និង ២០២៣ គម្រោងនេះត្រូវបានគាំទ្រដោយមិត្តនៅក្រៅប្រទេស ។

**គោលបំណង** ៖ គម្រោងបណ្ណាល័យផ្តល់ដល់សហគមន៍ក្នុងការទទួលបាននូវចំណេះដឹងតាមរយៈការអានសៀវភៅ។

**ទិសដៅ** ៖ ក្នុងអំឡុងឆ្នាំ ២០២៤ យ៉ាងតិចណាស់ មានហគមន៍ចំនួន ៦០០នាក់ ទទួលបានការអានសៀវភៅ។

**យុទ្ធសាស្ត្រ** ៖ ដោយទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុពីមិត្តភក្តិនៅបរទេស បណ្ណាល័យនឹងមានធនធានដើម្បីរក្សាប្រតិបត្តិការរបស់ខ្លួនតាមរយៈការបន្តផ្គត់ផ្គង់សៀវភៅសម្រាប់សហគមន៍សម្រាប់អាន។

**លទ្ធផលរំពឹងទុក៖** តាមរយៈការអានសៀវភៅ សហគមន៍ ជាពិសេសសិស្សានុសិស្ស នឹងទទួលបានចំណេះដឹង និងបង្កើតជំនាញដែលអាចអនុវត្តបានក្នុងវិស័យផ្សេងៗសម្រាប់ជីវិតរបស់ពួកគេ។

ផែនការប្រចាំឆ្នាំ ២០២៤ ចងក្រងដោយ ក្រុមការងារគ្រប់គ្រង
អង្គការមូលនិធិទ្រទ្រង់កុមារកម្ពុជា
រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ ២០២៤

| នាយប្រតិបត្តិ អង្គការ | ផ្នែក រដ្ឋបាល និង ហិរញ្ញវត្ថុ<br>ប្រធាន | គម្រោងអប់រំ<br>ប្រធាន | គម្រោងមត្តេយ្យសិក្សាសហគមន៍<br>អ្នកសម្របសម្រួល | ផ្នែក ហិរញ្ញវត្ថុ<br>គណនេយ្យករជាន់ខ្ពស់ |
|---|---|---|---|---|
| ហ៊ីង ច័ន្ទណារិទ្ធ | លោកស្រី ហៀង ឡាំងអេង | លោក រិទ្ធី ច័ន្ទតារា | លោកស្រី អឿ ស្រីម៉ៃ | លោកស្រី ឈិន ដាលីន |